

# តើខ្ញុំអាចប្រើសែក WIC ទិញអ្វីខ្លះ?

សែក WIC ធ្វើឲ្យងាយស្រួលសំរាប់អ្នក ដើម្បីផ្តល់អាហារមានសុខភាពល្អ ឆ្ងាញ់ពិសា ដែលធ្វើឲ្យអ្នកមានអារម្មណ៍ល្អ អំពីការផ្គត់ផ្គង់អាហារឲ្យគ្រួសាររបស់អ្នក ។ សែក WIC ក៏ងាយស្រួលប្រើផងដែរ ។ អ្នកគ្រាន់តែយកវាមកជាប់ខ្លួនអ្នក នៅពេលអ្នកទៅទិញម្ហូបអាហារ ហើយប្រើវាដើម្បីទទួលម្ហូបអាហារប្រកបដោយសុខភាពល្អ ដោយឥតគិតថ្លៃ រួមមាននូវ :

- ម្ហូបកូនង៉ែត
- អង្ករសំរូប
- ត្រីខកំប៉ុង
- អាហារក្រៀមៗ
- ឈីស្ស
- សណ្តែកក្រៀម ឬកំប៉ុង/សណ្តែកបារាំង
- ពងមាន
- ទឹកផ្លែឈើ
- ផ្លែឈើ និងបន្លែ
- ទឹកដោះគោកូនង៉ែត
- ទឹកដោះគោ
- ប៊ឺរសណ្តែកដី
- នំក្រៀបធ្វើពីម្សៅពោត
- នំប៉ុងធ្វើពីធញ្ញជាតិសុទ
- តៅហ៊ូ

តើអ្នកមានសំណួរឬទេ? សូមទាក់ទង WIC នៅថ្ងៃនេះ ដើម្បី ស្វែងយល់ថែមទៀត ។ ទូរស័ព្ទទៅការិយាល័យ WIC ដែល ស្ថិតនៅជិ តអ្នកបំផុត (មើលខាងខ្នង) ឬទូរស័ព្ទទៅលេខការផ្តល់ជូនគ្រួសារ 1-800-942-1007 ឬក៏មើល www.mass.gov/wic ។

ដើម្បីឲ្យបានដឹងអំពីកម្មវិធ WIC សូមទូរស័ព្ទទៅលេខ 1-800-942-1007 ឬកម្មវិធីមួយដែលស្ថិតនៅជិតអ្នក ។

## តំបន់ បុស្តុន

| | |
|---|---|
| Blue Hill Corridor | (617) 822-5584 |
| Brighton/Roslindale | (617) 254-0492 |
| Cambridge/Somerville | (617) 666-5059 |
| Chelsea/Revere | (617) 887-4340 |
| Dorchester North | (617) 825-8994 |
| Dorchester South | (617) 825-0805 |
| East Boston | (617) 568-6400 x0 |
| Jamaica Plain | (617) 983-6086 |
| Roxbury | (617) 989-3055 |
| South Boston | (617) 464-5850 |
| South Cove | (617) 521-6777 |
| South End | (617) 425-2070 |

## តំបន់ កាព

| | |
|---|---|
| Cape Cod | (800) 942-2445 |
| Outer Cape | (800) 675-1188 |

## ប៉ែក កណ្តាល

| | |
|---|---|
| Framingham/Waltham | (508) 620-1445 |
| North Central | (978) 345-6272 x1 |
| South Central | (508) 765-0139 |
| Worcester | (508) 860-7744 |

## ប៉ែក ឦសាន

| | |
|---|---|
| Lawrence | (978) 681-4960 |
| Lowell | (978) 454-6397 |
| North Shore | (781) 599-7290 |
| North Suburban | (781) 338-7578 |
| Northern Essex | (978) 374-2191 |

## ប៉ែក អាគ្នេយ

| | |
|---|---|
| Brockton | (508) 588-8241 |
| Fall River | (508) 679-9349 |
| New Bedford | (508) 997-1500 |
| Plymouth | (508) 747-4933 |
| Quincy | (617) 376-4190 |
| Taunton/Attleboro | (508) 823-6346 x227 |

## ប៉ែក ខាងលិច

| | |
|---|---|
| Berkshire North | (413) 445-9429 |
| Berkshire South | (413) 528-0457 |
| Franklin/Hampshire/No. Quabbin | (413) 376-1160 |
| Holyoke/Chicopee | (413) 534-2460 |
| Springfield North | (413) 737-8868 |
| Springfield South | (413) 693-1029 |

form #147

កម្មវិធីអាហារមានជីវជាតិ WIC • 1-800-WIC-1007
ក្រសួងសុខភាពសាធារណៈ នៃរដ្ឋម៉ាស្សាជូសេត
លេខ TDD/TTY: (617) 624-5992 • វ៉ិប : www.mass.gov/wic

ស្ថាប័ននេះ គឺជាអ្នកផ្តល់ និងជានិយោជកស្មើឱកាសគ្នា .











WIC



# ការផ្តល់ជូនគ្រួសារ អាហារដ៏ល្អៗ និង ច្រើនសន្លឹកថែមទៀត

Khmer

# តើកម្មវិធី WIC ជាអ្វី?

WIC គឺជាកម្មវិធីអាហារមានជីវជាតិ ដែលផ្តល់អាហារមានជីវជាតិ និងផ្តល់ការអប់រំសុខភាព ផ្តល់អាហារមានសុខភាពល្អ និងការបំរើផ្សេងៗទៀត ដោយឥតគិតថ្លៃសោះ សំរាប់គ្រួសារនៅរដ្ឋម៉ាស្សាជូសេត្ត ដែលមានសិទ្ធិទទួល ។ WIC ជាតំណាងឲ្យពាក្យ ស្ត្រី ទារក និងកុមារ (Women, Infants and Children) ។



## តើកម្មវិធី WIC ផ្តល់ជូនអ្វីខ្លះ?

គោលដៅរបស់កម្មវិធី WIC គឺដើម្បីជួយរក្សាស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅដោះកូន ព្រមទាំងក្មេងៗក្រោមអាយុ 5 ឆ្នាំ ឲ្យមានសុខភាពល្អ ។ ដើម្បីធ្វើការនេះ កម្មវិធី WIC ផ្តល់ :

- ការប្រឹក្សាអំពីអាហារមានជីវជាតិ ដោយផ្ទាល់ខ្លួន
- សែកសំរាប់ទិញអាហារមានសុខភាពល្អ ដោយឥតគិតថៃ
- ឱវាទសំរាប់ការបរិភោគល្អ ដើម្បីធ្វើឲ្យសុខភាពល្អប្រពៃឡើង
- ការបញ្ជូនទៅថែទាំរោគា និងការថែទាំធ្មេញ ការធានារ៉ាប់រងសុខភាព ការមើលថែក្មេង ទីលំនៅ និងជំនួយប្រេងឥន្ធនៈ ព្រមទាំងការបំរើផ្សេងៗទៀត ដែលអាចផ្តល់ផលប្រយោជន៍សំរាប់គ្រួសារទាំងមូល

ប៉ុន្តែមិនទាន់អស់នៅឡើយទេ!!! កម្មវិធី WIC ក៏ផ្តល់ថ្នាក់រៀនបំបៅដោះកូន ការគាំទ្រ មួយ-ទល់-មួយ អំពីការបំបៅដោះកូន ព្រមទាំងការត្រួតពិនិត្យចាក់ថ្នាំការពាររោគ និងការបញ្ជូនដែរ ។ កម្មវិធី WIC ក៏ផ្តល់ឱកាសឲ្យមាតាបិតា ដើម្បីនិយាយទៅកានមាតាបិតាដទៃទៀត អំពីអាហារមានជីវជាតិ និងប្រធានបទខាងសុខភាពផ្សេងៗទៀត ដែលជាសារៈសំខាន់ សំរាប់គ្រួសាររបស់គេ ផងដែរ ។



## តើកម្មវិធី WIC សំរាប់អ្នកណា?



កម្មវិធី WIC គឺសំរាប់ក្មេងៗនៃគ្រួសារ : ដែលរស់នៅជុំគ្នា និងមាតាបិតាម្នាក់ឯង, ធ្វើការ ឬមិនធ្វើការក្តី ។ បើសិនអ្នកជាឪពុក, ម្តាយ, ជីដូនជីតា, មាតាបិតាចិញ្ចឹម ឬអ្នកអាណាព្យាបាលពេញច្បាប់ផ្សេងទៀត នៃក្មេងក្រោមអាយុ 5 ឆ្នាំ អ្នកអាចដាក់ពាក្យសុំកម្មវិធី ជ សំរាប់កូនរបស់អ្នកបាន ។

អ្នកអាចចូលរួមក្នុងកម្មវិធី WIC បាន បើសិនជាអ្នក :

- រស់នៅក្នុងរដ្ឋម៉ាស្សាជូសេត្ត
- ត្រូវការនូវអាហារមានជីវជាតិ (បុគ្គលិកកម្មវិធី WIC អាចជួយអ្នកសំរេចអំពីការនេះ)
- ជាក្មេងក្រោមអាយុ 5 ឆ្នាំ ឬជាស្ត្រីមានផ្ទៃពោះ ឬជាស្ត្រីបំបៅដោះកូន និង
- គ្រួសារមានប្រាក់ចំណូលតិចជាងកំរិតរបស់ WIC

| ទំហំគ្រួសារ | ប្រចាំឆ្នាំ | ប្រចាំខែ | ប្រចាំអាទិត្យ |
|---|---|---|---|
| 1 | $20,036 | $1,670 | $386 |
| 2 | 26,955 | 2,247 | 519 |
| 3 | 33,874 | 2,823 | 652 |
| 4 | 40,793 | 3,400 | 785 |
| 5 | 47,712 | 3,976 | 918 |
| 6 | 54,631 | 4,553 | 1,051 |
| 7 | 61,550 | 5,130 | 1,184 |
| 8 | 68,469 | 5,706 | 1,317 |

បើសិនជាអ្នកមានផ្ទៃពោះ អ្នកគួរតែរាប់ខ្លួនអ្នកជាពីរនាក់ ។

កំរិតប្រាក់ចំណូលរបស់អ្នក មានសិទ្ធិទទួលកម្មវិធី WIC ជាស្វ័យប្រវត្តិ បើសិនជានៅពេលបច្ចុប្បន្ននេះ អ្នកកំពុងតែទទួល TAFDC, ហ្វ៊ូតស្តែម ឬ Masshealth ។ (ចំពោះសមាជិក Masshealth ដលមានគ្រួសារទទួលជំនួយ ឬការរ៉ាប់រង កំរិតប្រាក់ចំណូលពុំអាចទទួលជាស្វ័យប្រវត្តិបានឡើយ) ។ ក្មេងៗជាកូនចិញ្ចឹមក្រោមអាយុ 5 ឆ្នាំ ក៏មានសិទ្ធិទទួល កម្មវិធី WIC ជាស្វ័យប្រវត្តិដែរ ។

## តើបុរសអាចចូលរួមក្នុងកម្មវិធី WIC បានឬទេ?

កម្មវិធី WIC សូមស្វាគមន៍បុរស! កម្មវិធី WIC ទទួលស្គាល់តួនាទីដ៏សំខាន់ ដែលឪពុក ជីដូនជីតា មាតាបិតាចុង និងអ្នកអាណាព្យាបាលផ្សេងៗទៀត ក្នុងការថែរក្សាក្មេងៗ ។ យើង សូម-ជំរុញទឹកចិត្ត ឪពុក និងអ្នកមើលថែទាំងទៀតៗ នៃក្មេងៗក្រោមអាយុ 5 ឆ្នាំ ឲ្យចុះឈ្មោះ និងនាំក្មេងៗមកតាមការណាត់ជួប មកចូលរួមក្នុងការបង្ហឹកបង្វឹន ខាងអាហារមានជីវជាតិល្អ និងខាងសុខភាព ព្រមទាំងប្រើសែក WIC នៅតាមហាងលក់គ្រឿងឧបភោគ ។

## តើខ្ញុំដាក់ពាក្យសុំកម្មវិធី WIC របៀបណា?

សូមទូរស័ព្ទទៅការិយាល័យនៃកម្មវិធី WIC ក្នុងសហគមនរបស់អ្នក ដើម្បីណាត់ពេលជួប ឬទូរស័ព្ទទៅលេខ 1-800-942-1007 ។ ការិយាល័យកម្មវិធ WIC ជាច្រើន គឺបើកធ្វើការនៅពេលល្ងាច និងនៅថ្ងៃសៅរ៍ ដូច្នេះហើយអ្នកមិនបាចអាក់ខានទៅធ្វើការទេ ។ ការមកជួបដោយឥតណាត់ពេលជួបតែងតែស្វាគមន៍ជានិច្ច ។

**1-800-942-1007**